**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

# សាលក្រម

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងរាជធានីភ្នំពេញ

**តុលាការរដ្ឋប្បវេណី**

-សំណុំរឿងរដ្ឋប្បវេណីលេខ ៧៤៦

ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២០

-សាលក្រមលេខ......១១......"ទ"

-ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២១

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២០

**ចៅក្រមជំនុំជម្រះ**

-លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជី**

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

**-ដើមចោទ៖**

ឈ្មោះ [redacted] ឡាយខាន់ ហៅ [redacted] សុទ្ធារី ភេទស្រី កើតថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៥៤ សញ្ជាតិខ្មែរ មានអាសយដ្ឋាន [redacted] មាន មេធាវី [redacted] ជាមេធាវីតំណាងឱ្យអាណត្តិ។

## I. អង្គហេតុ និងចំណុចវិវាទ

### ក. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ៖

សុំសាលក្រមបញ្ជាក់ថាឈ្មោះ [redacted] ឡាយខាន់ និងឈ្មោះ [redacted] សុទ្ធារី ជាមនុស្សតែម្នាក់ ។

### ខ. ដំណើររឿងក្តី និងចំណុចវិវាទ

### ខ.១ ការសង្ខេបអំពីរឿងក្តី

ឈ្មោះ [redacted] ឡាយខាន់ និងឈ្មោះ [redacted] សុទ្ធារី ជាឈ្មោះពីរដែលបានប្រើប្រាស់ដោយមនុស្សម្នាក់។ នៅក្នុងឆ្នាំ២០១១ ដើមចោទបានទៅធ្វើអត្តសញ្ញាណបណ្ណដោយបានដាក់ឈ្មោះ [redacted] សុទ្ធារី ក្រោយមក នៅឆ្នាំ២០១៦ ដើមចោទបានទៅធ្វើអត្តសញ្ញាណបណ្ណសារជាថ្មី ដោយដាក់ឈ្មោះ [redacted] ឡាយខាន់ វិញ។ ដោយហេតុថាដើមចោទប្រើឈ្មោះពីរ ជាហេតុធ្វើឱ្យដើមចោទមានការលំបាកក្នុងការធ្វើឯកសារផ្លូវការ ហើយដើម្បីជៀសវាងមានការភាន់ច្រឡំពីអាជ្ញាធរ ឬស្ថាប័ននានា ទើបដើមចោទស្នើសុំសាលក្រមនេះដើម្បីទៅប្រើប្រាស់ជាផ្លូវការ និងបានត្រឹមត្រូវតាមច្បាប់។

### ខ.២ អង្គហេតុដែលគ្មានវិវាទ

សុំបញ្ជាក់ថាឈ្មោះ [redacted] ឡាយខាន់ និងឈ្មោះ [redacted] សុទ្ធារី ជាមនុស្សតែម្នាក់ ។

### ខ.៣ ចំណុចវិវាទ

ដើមចោទសុំចេញសាលក្រមទទួលស្គាល់ជាមនុស្សតែម្នាក់ តើមានមូលហេតុត្រឹមត្រូវសមហេតុផលដើម្បីសម្រេច បានដែរឬទេ ?



Scanned with CamScanner

ខ.៤ ការអះអាងរបស់ដើមចោទ

-សេចក្តីថ្លែងការណ៍របស់មេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ៖

យើងខ្ញុំសូមបញ្ជាក់ជូនតុលាការមេត្តាជ្រាបថា បច្ចុប្បន្នកូនក្តីរបស់យើងខ្ញុំឈ្មោះ [redacted] ឡាយខាន់ ហៅ [redacted] សុទ្ធារី គាត់បាននឹងកំពុងប្រើប្រាស់ឈ្មោះពីររហូតមក។ ដើម្បីជៀសវាងការភាន់ច្រឡំ និងការលំបាកក្នុងការដំណើរការឯកសារផ្លូវការជាមួយនឹងអាជ្ញាធរមានសមត្ថកិច្ចខាងស្ថាប័ននានា ដែលត្រូវធ្វើការពាក់ព័ន្ធនឹងឯកសារអត្តសញ្ញាណរបស់កូនក្តីយើងខ្ញុំ ទើបកូនក្តីយើងខ្ញុំសម្រេចចិត្តដាក់ពាក្យបណ្តឹងមកតុលាការ។ ដូច្នេះ ដើម្បីជាភស្តុតាងបង្ហាញអំពីឈ្មោះពីរជាមនុស្សតែម្នាក់ គឺមានឯកសារភស្តុតាងដូចបានផ្តល់ជូនរួមមាន៖ សេចក្តីចម្លងសំបុត្រកំណើតលេខ ៣៤២២ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០០៤ របស់ឈ្មោះ [redacted] ឡាយខាន់ មានថ្ងៃខែឆ្នាំកំណើតថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៥៤, សៀវភៅស្នាក់នៅលេខ ២៣៤៤-១៩៩F ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០០៧ របស់ឈ្មោះ [redacted] សុទ្ធារី មានថ្ងៃខែឆ្នាំកំណើតថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៥៤, អត្តសញ្ញាណបណ្ណលេខ ០១០០៤២៩៧០ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១១ របស់ឈ្មោះ [redacted] សុទ្ធារី មានថ្ងៃខែឆ្នាំកំណើត ថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៥៤, សៀវភៅស្នាក់នៅលេខ ៤០០៩-២១៤០H ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៦ របស់ឈ្មោះ [redacted] ទ្រី ដែលមានប្រពន្ធឈ្មោះ [redacted] ឡាយខាន់ ឬ [redacted] សុទ្ធារី មានថ្ងៃខែឆ្នាំកំណើត ថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៥៤, អត្តសញ្ញាណបណ្ណលេខ ០១០៤២៧១២(០1) ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ របស់ឈ្មោះ [redacted] ឡាយខាន់ មានថ្ងៃខែឆ្នាំកំណើត ថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៥៤, លិខិតបញ្ជាក់លេខ ៤៤/២០១៧ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧ របស់ចៅសង្កាត់មនោរម្យ([redacted] សារឿន) និងលិខិតបញ្ជាក់លេខ ០៨០/២០២០ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០២០ របស់ចៅសង្កាត់មនោរម្យ([redacted] សារឿន) ដែលបញ្ជាក់ថាឈ្មោះ [redacted] ឡាយខាន់ និងឈ្មោះ [redacted] សុទ្ធារី ជាមនុស្សតែម្នាក់។

## II.ការពិនិត្យភស្តុតាង

-ភស្តុតាងជាឯកសាររបស់គូភាគី៖

១. សេចក្តីចម្លងសំបុត្រកំណើតលេខ ៣៤២២ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០០៤ របស់ឈ្មោះ [redacted] ឡាយខាន់ (ថតចម្លង)។

២. សៀវភៅស្នាក់នៅលេខ ២៣៤៤-១៩៩F ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០០៧ របស់ឈ្មោះ [redacted] សុទ្ធារី (ថតចម្លង)។

៣. អត្តសញ្ញាណបណ្ណលេខ ០១០០៤២៩៧០ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១១ របស់ឈ្មោះ [redacted] សុទ្ធារី (ថតចម្លង)។

៤. សៀវភៅស្នាក់នៅលេខ ៤០០៩-២១៤០H ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៦ របស់ឈ្មោះ [redacted] ទ្រី (ថតចម្លង)។

៥. អត្តសញ្ញាណបណ្ណលេខ ០១០៤២៧១២(០1) ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ របស់ឈ្មោះ [redacted] ឡាយខាន់ (ថតចម្លង)។

៦. លិខិតបញ្ជាក់លេខ ៤៤/២០១៧ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧ របស់ចៅសង្កាត់មនោរម្យ([redacted] សារឿន) (ថតចម្លង)។

៧. លិខិតបញ្ជាក់លេខ ០៨០/២០២០ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០២០ របស់ចៅសង្កាត់មនោរម្យ[redacted] សារឿន) (ថតចម្លង)។

## III.សំអាងហេតុ

ផ្អែកតាមលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យភស្តុតាង តុលាការ យល់ឃើញថា៖

១. ដើមចោទឈ្មោះ [redacted] ឡាយខាន់ ហៅ [redacted] សុទ្ធារី បានដាក់ពាក្យសុំឱ្យតុលាការចេញសាលក្រមទទួលស្គាល់ឈ្មោះ [redacted] ឡាយខាន់ និងឈ្មោះ [redacted] សុទ្ធារី ថាជាមនុស្សតែម្នាក់។ បើតាមការពិនិត្យមើលលើសេចក្តីបញ្ជាក់របស់មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទបានបញ្ជាក់ថា កូនក្តីរបស់ខ្លួនបច្ចុប្បន្នកំពុងប្រើប្រាស់ឈ្មោះពីរគឺ [redacted] ឡាយខាន់ និងឈ្មោះ [redacted] សុទ្ធារី ក្រោយមកដើម្បីជៀសវាងការភាន់ច្រឡំ និងការលំបាកក្នុងការដំណើរការឯកសារផ្លូវការជាមួយនឹងអាជ្ញាធរមានសមត្ថកិច្ចខាងស្ថាប័ននានា ដែលត្រូវធ្វើការពាក់ព័ន្ធនឹងឯកសារអត្តសញ្ញាណរបស់កូនក្តីខ្លួន ទើបសម្រេចចិត្តដាក់ពាក្យបណ្តឹងតែម្តង។



Scanned with CamScanner

តាមការពិនិត្យលើឯកសារជាភស្តុតាងលើសេចក្តីចម្លងសំបុត្រកំណើតលេខ ៣៤២២ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០០៤ របស់ឈ្មោះ [redacted] ឡាយខាន់, សៀវភៅស្នាក់នៅលេខ ២៣៤៤-១៩៩F ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០០៧ របស់ឈ្មោះ [redacted] សុទ្ធារី, អត្តសញ្ញាណបណ្ណលេខ ០១០០៤២៩៧០ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១១ របស់ឈ្មោះ [redacted] សុទ្ធារី, សៀវភៅស្នាក់នៅលេខ ៤០០៩-២១៤០H ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៦ របស់ឈ្មោះ [redacted] ទ្រី ដែលមានប្រពន្ធឈ្មោះ [redacted] ឡាយខាន់ ឬ [redacted] សុទ្ធារី, អត្តសញ្ញាណបណ្ណលេខ ០១០៤២៧១២(០១) ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ របស់ឈ្មោះ [redacted] ឡាយខាន់។

-យោងតាមលិខិតបញ្ជាក់លេខ ៤៤/២០១៧ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧ របស់ចៅសង្កាត់មនោរម្យ [redacted] សារឿន) និងលិខិតបញ្ជាក់លេខ ០៨០/២០២០ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០២០ របស់ចៅសង្កាត់មនោរម្យ( [redacted] សារឿន) ដែលបញ្ជាក់ថាឈ្មោះ [redacted] ឡាយខាន់ និងឈ្មោះ [redacted] សុទ្ធារី ជាមនុស្សតែម្នាក់។ ការលើកឡើងរបស់ដើមចោទឈ្មោះ [redacted] **ឡាយខាន់ ហៅ** [redacted] **សុទ្ធារី** ជាមានមូលដ្ឋានច្បាស់លាស់ត្រឹមត្រូវ ដែលអាចឱ្យតុលាការជឿបាន ។

-តាមការពិនិត្យលើឯកសារ និងការបញ្ជាក់របស់ចៅសង្កាត់ ព្រមទាំងការបញ្ជាក់របស់សាម៉ីខ្លួន ទៅលើឯកសារជាភស្តុតាង មានភាពស៊ីសង្វាក់ជាមួយគ្នាទៅលើអត្តសញ្ញាណរបស់ឈ្មោះ [redacted] ឡាយខាន់ និងឈ្មោះ [redacted] សុទ្ធារី គឺជាមនុស្សតែម្នាក់។ ដើម្បីឱ្យមានភាពងាយស្រួល ដូចការបញ្ជាក់របស់ដើមចោទថា ខ្លួនមានការលំបាកក្នុងការប្រើប្រាស់ឯកសារ គប្បីតុលាការទទួលស្គាល់ និងបញ្ជាក់តាមការស្នើសុំរបស់អ្នកដាក់ពាក្យសុំមកពិនិត្យពិចារណា។

-ទទួលស្គាល់ពាក្យបណ្តឹង ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២០ របស់ឈ្មោះ [redacted] ឡាយខាន់ ហៅ [redacted] សុទ្ធារី ត្រឹមត្រូវតាមគតិច្បាប់។

**២. ចំពោះប្រាក់ប្រដាប់ក្តី៖** គប្បីតុលាការសម្រេចតាមមាត្រា៦៤ កថាខណ្ឌ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី "ប្រាក់ប្រដាប់ក្តី គឺជាបន្ទុករបស់ភាគីចាញ់ក្តី ។ ក្នុងករណីដែលបានចាញ់ក្តីតែមួយភាគទេ តុលាការត្រូវសម្រេចនូវបន្ទុកដែលភាគីម្នាក់ៗ ត្រូវទទួលដោយឆន្ទានុសិទ្ធិរបស់ខ្លួន"។

## IV.សេចក្តីសម្រេចបញ្ចប់

១. ទទួលស្គាល់ឈ្មោះ [redacted] **ឡាយខាន់** និងឈ្មោះ1 [redacted] **សុទ្ធារី** ជាមនុស្សតែម្នាក់។

២. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ ស្របតាមមាត្រា៦៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

សាលក្រមនេះត្រូវបានប្រកាសជាសាធារណៈនៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២១ ។ ក្នុងករណីដែល ប្តឹងឧទ្ធរណ៍ត្រូវតែធ្វើក្នុងរយៈពេល ០១(មួយ)ខែ គិតចាប់ពីថ្ងៃបានទទួលការបញ្ជូនលិខិតសាលក្រមនេះ។

**ចៅក្រម**

**ហត្ថលេខា និងត្រា** [redacted]

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

**បានឃើញ**

**ចៅក្រម**

[redacted]

ថ្ងៃព្រហស្បតិ៍ ១៥កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២១

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner